01180560

០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ / N°: D174

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No:003/07-09-2009-ECCC-OCIJ**

# កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង

# Written Record of Initial Appearance

# Procès-Verbal d'Interrogatoire de Première Comparution

នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ៩.៣០ ព្រឹក ការបង្ហាញខ្លួនលើកដំបូងរបស់ លោក មាស មុត បានធ្វើឡើងនៅបាត់ដំបង ដោយមានវត្តមានដូចខាងក្រោម៖

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander

ក្រឡាបញ្ជី៖ អ្នកស្រី ឆាយ ច័ន្ទលីដា

ជនសង្ស័យ៖ លោក មាស មុត

សម្រាប់ក្រុមមេធាវីការពារក្តីរបស់ លោក មាស មុត មាន៖
លោក អាង ឧត្តម សហមេធាវីជាតិ
លោក Michael G. KARNAVAS សហមេធាវីអន្តរជាតិ
អ្នកស្រី ឈូក គឹមម៉ៅ អ្នកគ្រប់គ្រងសំណុំរឿង

បុគ្គលិក ក.ស.ច.ស មាន៖
លោក Phillip Weiner មន្ត្រីច្បាប់
លោក Max Galler មន្ត្រីច្បាប់
លោក សួរ សុខាល័យ អ្នកបកប្រែភាសាដែលបានស្បថ នៅ អ.វ.ត.ក

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 12 / 2015
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

01180561

០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស លេខ៖ D174

លោក ញ៉ែត សុខហេង ជំនួយការផ្នែកកិច្ចការសាធារណៈ នៅ អ.វ.ត.ក

លោក Mark PETERS ប្រធានផ្នែក ICT នៅ អ.វ.ត.ក

កូនប្រុសរបស់លោក មាស មុត ឈ្មោះ [redacted] ក៏អមដំណើរមកជាមួយគាត់ដែរ

អ្នកដែលមានវត្តមានទាំងអស់ ត្រូវបានជូនដំណឹងថា ការបង្ហាញខ្លួនលើកដំបូងនេះនឹងត្រូវថតយកសំឡេង/រូបភាព។

លោក មាស មុត បានបញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួនរបស់គាត់ដូចខាងក្រោម៖

ឈ្មោះ៖ មាស មុត
ថ្ងៃខែឆ្នាំកំណើត៖ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៣៨
ស្រុកកំណើត៖ ភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត
សញ្ជាតិ៖ ខ្មែរ
មុខរបរ៖ កសិករចូលនិវត្ត
ឈ្មោះឪពុក៖ [redacted]
ឈ្មោះម្តាយ៖ [redacted]
ឈ្មោះគ្រួសារ៖ [redacted]
ចំនួនកូន៖ ៤ នាក់

គាត់ បានប្រកាសថា គាត់ចេះអាន សរសេរ និងយល់ភាសាខ្មែរ ប៉ុន្តែ គាត់មិនចេះអាន សរសេរ ឬយល់ភាសាអង់គ្លេស ឬភាសាបារាំងទេ។ អាស្រ័យហេតុនេះ ច្បាប់ដើមនៃកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះ ត្រូវបានធ្វើប្រតិចារិកជាភាសាខ្មែរ ដោយអ្នកស្រី ឆាយ ច័ន្ទលីដា ជាក្រឡាបញ្ជី។

លោក មាស មុត ត្រូវបានជូនដំណឹង ថា៖

- គាត់មានសិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ ហើយគ្មានសេចក្តីសន្និដ្ឋានអវិជ្ជមានណាមួយអាចធ្វើឡើងដោយសារគាត់ប្រើប្រាស់សិទ្ធិនេះទេ។
- គាត់មានសេរីភាពក្នុងការធ្វើសេចក្តីសន្និដ្ឋានមុនពេល ឬបន្ទាប់ពីការជូនដំណឹងអំពីបទចោទប្រកាន់។

- គាត់មានសិទ្ធិទទួលបានតំណាងផ្លូវច្បាប់ ហើយ
- គាត់អាចពិគ្រោះជាមួយសហមេធាវីរបស់គាត់មុនពេលគាត់ធ្វើសេចក្តីសន្និដ្ឋានបែបនោះ។

ទាំងជនសង្ស័យ ទាំងសហមេធាវីរបស់គាត់ បានសម្រេចមិនធ្វើសេចក្តីសន្និដ្ឋាន ឬក៏ដាក់សេចក្តីសង្កេតនៅពេលនេះទេ។

ស.ច.ស.អ បានជូនដំណឹង ជនសង្ស័យ អំពីការចោទប្រកាន់អំពីអំពើឧក្រិដ្ឋដែល ស.ច.ស.អ បានទទួលពិនិត្យពីការិយាល័យសហព្រះរាជអាជ្ញា("ក.ស.ព") តាមរយៈដីកាសន្និដ្ឋានចំនួនពីរ។ ដីកាសន្និដ្ឋានទាំងនេះគឺ

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") និង
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")។

ជនសង្ស័យត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដែលបានចោទទាំងនោះ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់របស់កម្ពុជាប្រជាធិបតេយ្យ ឬក៏ជាជនទទួលខុសត្រូវខ្ពស់បំផុតម្នាក់ចំពោះឧក្រិដ្ឋកម្មដែលបានចោទទាំងនោះ។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា អំពើឧក្រិដ្ឋដែលបានចោទដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបាន ក.ស.ព កំណត់លក្ខណៈបទល្មើស ដូចខាងក្រោម៖

- **ការរំលោភលើមាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** (មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ)
- **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**(ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត) និង

- **អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩**(ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ~~ការដកហូតសិទ្ធិ~~ ឬការផ្លាស់ទីលំនៅ ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)។ និរទេស

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា ស.ច.ស.អ មិនជាប់កាតព្វកិច្ចត្រូវធ្វើតាមការកំណត់បទល្មើសដូចដែល ក.ស.ព បានសម្រេចទេ។

អាស្រ័យហេតុនេះ ស.ច.ស.អ បានជូនដំណឹង មាស មុត ថែមទៀតថា ដោយផ្អែកតាមភស្តុតាងដែលមាននៅក្នុងសំណុំរឿងរហូតមកដល់ថ្ងៃនេះ ឧក្រិដ្ឋកម្មចំនួនពីរដែល ក.ស.ព បានចោទ នឹងត្រូវកំណត់លក្ខណៈបទល្មើសថែមទៀត៖

- ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ក្នុងដែនទឹក និង នៅលើកោះនានាដែលរបបកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន នៅកថាខណ្ឌ ៥៩ ដល់ ៦១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ១៥ និង ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម នឹងត្រូវកំណត់លក្ខណៈបទល្មើសបន្ថែមទៀតថាជាអំពើប្រល័យពូជសាសន៍ យោងតាម**អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**។
- អំពើនានាសម្រាប់បទចោទស្តីពីអំពើអមនុស្សធម៌ដទៃទៀត(អាពាហ៍ពិពាហ៍ដោយបង្ខំ) នៅកថាខណ្ឌ ២០ ដល់ ២៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម នឹងត្រូវកំណត់លក្ខណៈបទល្មើសបន្ថែមទៀតដើម្បីបញ្ចូលការរំលោភលើផ្លូវភេទ។

បទល្មើសទាំងនេះមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៤, ៥,៦, ២៩ និង៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

មាស មុត ត្រូវបានជូនដំណឹងថា នៅពេលនេះ មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថាគាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋ យ៉ាងហោចណាស់ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម មានដូចខាងក្រោម៖

១. នៅមន្ទីរសន្តិសុខផ្សេងៗ ជាពិសេស មន្ទីរសន្តិសុខ ស-២១ ហៅ ទួលស្លែង- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ និង ៦៥ ដល់ ៦៦។

២. ឧក្រិដ្ឋកម្មមកលើសមាជិកកងពលលេខ ១៦៤, ៥០២, ១១៧ និង ៣១០-ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៤ ដល់ ៥៤, ៦៥, ៦៦ និង ៨៦គ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១២ ដល់ ១៤។

៣. នៅមន្ទីរសន្តិសុខវត្តឥន្ទញាណ- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៥ ដល់ ៥៧ និង ៨៦គ។

៤. នៅការដ្ឋានស្ទឹងហាវ - ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៨ និង ៨៦គ។

៥. ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ក្នុងដែនទឹក និង នៅលើកោះនានាដែលរបបកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន - ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៩ ដល់ ៦១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៥ និង ១៧។

៦. នៅសហករណ៍តំបន់រាម រាប់បញ្ចូល ប៉ុន្តែមិនកំណត់នៅត្រឹម៖

ក. ការដ្ឋាននៅកងកេង និងបិតត្រាំង

ខ. ទីតាំងសម្លាប់មនុស្សចម្ការដូរេន និង

គ. មន្ទីរសន្តិសុខទឹកសាប

៧. នៅកំពង់សោម-ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ២០-២៤។

មាស មុត ត្រូវបានជូនដំណឹងថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ជាពិសេស ក្នុងអតីតឋានៈរបស់គាត់ជា៖

- សមាជិកនៃអគ្គសេនាធិការ
- មេបញ្ជាការកងពលលេខ ១៦៤ រួមមានកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ
- និងរដ្ឋអំណាចស៊ីវិលខ្ពស់បំផុតនៅតំបន់ស្វយ័តកំពង់សោម។

<u>អំពើប្រល័យពូជសាសន៍</u>

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តមកលើជនជាតិវៀតណាម

នៅលើកោះនានាដែល កម្ពុជាប្រជាធិបតេយ្យ បានអះអាងថាជារបស់ខ្លួន ជាពិសេស កោះត្រល់ និង កោះពូលូវៃ ប៉ុន្តែមិនកំណត់នៅត្រឹមកោះទាំងនោះទេ។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ៥៩ ដល់ ៦១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ១៥ និង ១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា គាត់អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកនៃក្រុមជនជាតិ និងជាតិពិន្ទុនោះ តាមរយៈទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្តិតាមរយៈ៖

- សហឧក្រិដ្ឋកម្មរួម ( "សហឧក្រិដ្ឋកម្មរួម ប្រភេទទី ១")
- ឬក៏តាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬក៏តាមរយៈការទទួលខុសត្រូវថ្នាក់លើ។

ហើយ មាស មុត ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទល្មើសខាងលើនេះ។

<u>ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធដែលសំដៅលើប្រជាជនស៊ីវិល ដោយមូលហេតុសញ្ជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនា។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោមនៅទីតាំងដូចខាងក្រោម៖

១) <u>មន្ទីរសន្តិសុខនានា ជាពិសេស មន្ទីរសន្តិសុខ ស-២១</u> ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ និង ៦៥ ដល់ ៦៦។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន) និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ"សមាសភាពមិនល្អ" "ខ្មាំង

ផ្ទៃក្នុង" និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេស តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

២) <u>ការបោសសម្អាតកងពលលេខ ១៦៤, ៥០២, ៣១០ និង ១១៧-</u> ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៤៤ ដល់ ៥៤, ៦៥, ៦៦ និង ៨៦គ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១២ ដល់ ១៤។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ "សមាសភាពមិនល្អ" "ខ្មាំងផ្ទៃក្នុង"និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេស តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង។

*ទម្រង់នៃការទទួលខុសត្រូវទាក់ទងនឹងកងពលលេខ ១៦៤ និង ១១៧៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

*ទម្រង់នៃការទទួលខុសត្រូវទាក់ទងនឹងកងពលលេខ ៥០២ និង ៣១០៖*

- ការប្រព្រឹត្តិតាមរយៈ សហឧក្រិដ្ឋកម្មរួម ប្រភេទទី ១ ឬ
- តាមរយៈការរៀបចំផែនការ។

៣) <u>មន្ទីរសន្តិសុខវត្តឥន្ទញាណ</u> -ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥៥ ដល់ ៥៧ និង ៨៦គ។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន) និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ"សមាសភាពមិនល្អ" "ខ្មាំងផ្ទៃក្នុង" និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេសតាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូរជាមនុស្ស ដោយសារស្ថានភាពនៃការឃុំខ្លួន)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

៤) <u>ការដ្ឋានស្មឹងហាវ</u> -ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ៥៨ និង៨០គ។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ពលកម្មដោយបង្ខំ និងការប្រព្រឹត្តិអមនុស្សធម៌) និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ"សមាសភាពមិនល្អ" "ខ្មាំងផ្ទៃក្នុង" និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេសតាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ពលកម្មដោយបង្ខំ និងការប្រព្រឹត្តិអមនុស្សធម៌)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា

- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

៥) ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យក្នុងដែនទឹក និង នៅលើកោះនានា ដែលរបបកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន - ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥៩ ដល់ ៦១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៥ និង ១៧។

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ) និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍មកលើជនបរទេស ជាពិសេស ជនជាតិថៃ និងវៀតណាម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

៦) សហករណ៍តំបន់រាម -ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៨២,៨៦ក និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ៦ ដល់ ១១, ១៦, ១៨ និង១៩

ក. ការដ្ឋានទៅកងកេង និងបិតត្រាំង៖

*ឧក្រិដ្ឋកម្ម៖* ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន ពលកម្មដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ “សមាសភាពមិនល្អ” “ខ្មាំងផ្ទៃក្នុង” និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេស និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍មកលើជនបរទេស ជាពិសេស

ជនជាតិថៃ និងវៀតណាម តាមរយៈបទល្មើសនៃការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូរជាមនុស្ស ដោយសារស្ថានភាពនៃការឃុំខ្លួន ពលកម្មដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

ខ. <u>ទីតាំងសម្លាប់មនុស្សចម្ការធ្មរេន៖</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត(ការបាត់ខ្លួនដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើ"សមាសភាពមិនល្អ" "ខ្មាំងផ្ទៃក្នុង" និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេស និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍មកលើជនបរទេស ជាពិសេស ជនជាតិថៃ និងវៀតណាម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត(ការបាត់ខ្លួនដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

គ. <u>មន្ទីរសន្តិសុខទឹកសាប</u>

*ឧក្រិដ្ឋកម្ម៖* ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូរជាមនុស្ស ដោយសារស្ថានភាពនៃការឃុំខ្លួន ពលកម្មដោយបង្ខំ) ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ

នយោបាយមកលើ"សមាសភាពមិនល្អ" "ខ្មាំងផ្ទៃក្នុង" និងមនុស្សដែលជាប់ទាក់ទងជាមួយនឹងរបបមុន ឬបរទេស និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុពូជសាសន៍មកលើជនបរទេស ជាពិសេស ជនជាតិថៃ និងវៀតណាម តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត(ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សដោយសារស្ថានភាពនៃការឃុំខ្លួន ពលកម្មដោយបង្ខំ)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

៧) <u>អាពាហ៍ពិពាហ៍ដោយបង្ខំ និងឧក្រិដ្ឋកម្មពាក់ព័ន្ធនៃការរំលោភលើផ្លូវភេទនៅកំពង់សោម</u> - ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ២០ - ២៤

*ឧក្រិដ្ឋកម្ម៖* អំពើអមនុស្សធម៌ដទៃទៀត (តាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភលើផ្លូវភេទ)។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្តិ តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

**<u>អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ</u>**

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងមកលើជនជាតិថៃ និងវៀតណាម នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងព្រះរាជាណាចក្រថៃ ចាប់ពីខែ មីនា ឆ្នាំ ១៩៧៥ ដល់ខែ កក្កដា ឆ្នាំ ១៩៧៨ និង

រវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងសាធារណរដ្ឋវៀតណាម ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា គាត់អាចទទួលខុសត្រូវចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដូចខាងក្រោម នៅទីតាំងដូចខាងក្រោម តាមរយៈការទទួលខុសត្រូវដែលបានបង្ហាញដូចខាងក្រោម៖

១) <u>មន្ទីរសន្តិសុខនានា ជាពិសេស មន្ទីរសន្តិសុខ ស-២១</u> - ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ និង ៦៥ ដល់ ៦៦

*ឧក្រិដ្ឋកម្ម៖* ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា
- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

៤ ~~២)~~ <u>ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ</u> -ក្នុងដែនទឹក និង នៅលើកោះនានា ដែលរបបកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥៩ ដល់ ៦១ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១៥ និង ១៧

*ឧក្រិដ្ឋកម្ម៖* ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម។

*ទម្រង់នៃការទទួលខុសត្រូវ៖*

- ការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម ប្រភេទទី ១
- ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា

- ឬតាមរយៈការទទួលខុសត្រូវថ្នាក់លើ។

**ការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦**

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា គាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា គាត់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទមនុស្សឃាតដោយចេតនា ដែលបានប្រព្រឹត្តនៅទីតាំងដូចខាងក្រោមតាមរយៈទម្រង់នៃការទទួលខុសត្រូវដូចខាងក្រោម៖

១. មន្ទីរសន្តិសុខនានា ជាពិសេស មន្ទីរសន្តិសុខ ស-២១ តាមរយៈការប្រព្រឹត្តិ (សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

២. ការបោសសម្អាតកងពលនានា

ក. កងពលលេខ ១៦៤ និង ១១៧ តាមរយៈការប្រព្រឹត្តិ(សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

ខ. កងពលលេខ ៥០២ និង ៣១០ តាមរយៈការប្រព្រឹត្តិ(សហចារី) ឬតាមរយៈការរៀបចំផែនការ។

៣. មន្ទីរសន្តិសុខវត្តឥន្ទញាណ តាមរយៈការប្រព្រឹត្តិ(សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

៤. ការដ្ឋានស្ទឹងហាវ តាមរយៈការប្រព្រឹត្តិ(សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

៥. ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពជើងទឹក នៅដែនទឹក និងតាមកោះនានាដែលកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន តាមរយៈការប្រព្រឹត្តិ (សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

៦. ទីតាំងសម្លាប់មនុស្សចម្ការធូងន និងមន្ទីរសន្តិសុខទឹកសាប ដែលមានទីតាំងនៅតំបន់រាម តាមរយៈការប្រព្រឹត្តិ(សហចារី) ឬតាមរយៈការរៀបចំផែនការ ឬការបញ្ជា។

## សហឧក្រិដ្ឋកម្មរួម

មានភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា សហឧក្រិដ្ឋកម្មរួម បានកើតឡើងយ៉ាងហោចណាស់ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ហើយសមាជិកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ រួមមាន ប៉ុន្តែមិនកំណត់នៅត្រឹម៖ ស៊ុន សេន, ស៊្វ ម៉េត, ឈិត ជឿន ហៅ តា ម៉ុក, មាស មុត, ប្រធានកងពលនានារបស់មជ្ឈិមបក្ស និងសមាជិកជាន់ខ្ពស់នៃអគ្គសេនាធិការរបស់ ក.ប.ក ដែលសុទ្ធតែបានចូលរួមគោលបំណងឧក្រិដ្ឋកម្មរួមក្នុងការអនុវត្តគោលនយោបាយដូចខាងក្រោមរបស់ ប.ក.ក តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក៖

១) ការបង្កើត និងដំណើរការ "សហករណ៍" និងការដ្ឋានពលកម្មដោយបង្ខំ

២) "ការកសាង""សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង"ទាំងនៅក្នុងជួរកងទ័ព ទាំងនៅក្រៅជួរកងទ័ព

៣) ការដាក់មុខសញ្ញាលើក្រុមជាក់លាក់នានា ជាពិសេស ជនជាតិវៀតណាម និងថៃ ឬជនដែលមានសញ្ជាតិវៀតណាម និងថៃ (ពិតប្រាកដ ឬគ្រាន់តែគេយល់ឃើញថាជនជាតិ/សញ្ជាតិវៀតណាម និងថៃ) រាប់បញ្ចូលទាំងទាហាន ឬអតីតទាហាន ជនស៊ីវិល និងជនបរទេសដែលធ្វើដំណើរនៅក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យ និង

៤) ការរៀបចំអាពាហ៍ពិពាហ៍ឱ្យជនស៊ីវិល និងសមាជិក ក.ប.ក ដោយបង្ខំ។

ស.ច.ស.អ បានបញ្ជាក់ថា សហឧក្រិដ្ឋកម្មរួមដែលគាត់បានកំណត់នេះ គឺកាត់បន្ថយវិសាលភាព និងផ្នែកផ្សេងៗពីសហឧក្រិដ្ឋកម្មរួម ដែលជាបទចោទនៅក្នុងដីកាសម្រេចចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥។

## ការបង្ហាញអំពីទីតាំងឧក្រិដ្ឋកម្មដែលមិនត្រូវស៊ើបអង្កេតបន្ថែមទៀត

ស.ច.ស.អ បានប្រកាសថា បច្ចុប្បន្ននេះ គាត់កំពុងពិចារណាមិនស៊ើបអង្កេតថែមទៀតលើការចោទប្រកាន់ដូចខាងក្រោម ហើយនឹងអញ្ជើញភាគីទាំងអស់ក្នុងពេលវេលាសមស្រប ដើម្បីធ្វើបទបង្ហាញអំពីបញ្ហានេះ៖ ៤ ៥

១) មន្ទីរសន្តិសុខ ស-២១ កថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

២) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង កថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

01180574



៣) ប្រទេសវៀតណាម ក្រៅពីកោះនានា ដែល កម្ពុជាប្រជាធិបតេយ្យ បានអះអាងជារបស់ខ្លួន និងព្រំដែនភាគខាងកើត កថាខណ្ឌ ៦២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

៤) គុកលេខ ៨១០ កថាខណ្ឌ ៦៣ និង ៦៤នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៥) មន្ទីរសន្តិសុខ ក.ប.ក ផ្សេងទៀតដែលមិនបានកំណត់អត្តសញ្ញាណ កថាខណ្ឌ ៦៥នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៦) ទីតាំងសម្លាប់មនុស្ស ស្ទឹងតូច កថាខណ្ឌ ៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៧) ការចូលរួមរបស់ ក.ប.ក នៅក្នុងការបោសសម្អាតភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា កថាខណ្ឌ ៦៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

កំណត់ហេតុហេតុនេះត្រូវបានឈប់សម្រាកនៅម៉ោង ១០:១១ និងបន្តទៀតនៅម៉ោង ១០:២១ ។

<u>បទចោទប្រកាន់ដែលត្រូវលុបចោល</u>

ស.ច.ស.អ បានប្រកាសថា បទចោទប្រកាន់ដូចខាងក្រោមដែលបានធ្វើឡើង*ដោយកំបាំងមុខ* នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ("ដីកាសម្រេចថ្ងៃទី ៣ ខែ មីនា") ត្រូវបានលុបចោល៖

១) បទចោទប្រកាន់អំពីការធ្វើទារុណកម្មនៅវត្តឥន្ទញាណ យោងតាមមាត្រា ៥០០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ដូចបានបង្ហាញនៅកថាខណ្ឌ ៤ នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងការចោទប្រកាន់នៅកថាខណ្ឌ ៥៥ ដល់ ៥៧ និងកថាខណ្ឌ ៨៦គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

២) បទចោទប្រកាន់អំពីមនុស្សឃាតដោយចេតនា ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ដូចបានបង្ហាញនៅកថាខណ្ឌ ៣(គ)នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ១២ ដល់ ១៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៣) បទចោទប្រកាន់ទាំងអស់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងនឹងកម្មាភិបាលស៊ីវិលនៅតំបន់ ៥០៥ ខេត្តក្រចេះ ដូចបានបង្ហាញនៅកថាខណ្ឌ ៧(គ)នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ១២ ដល់ ១៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៤) បទចោទប្រកាន់ទាំងអស់អំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការបោសសម្អាតជនដែលត្រូវបានចាត់ទុកថាជាខ្មាំង និងជាជនក្បត់ នៅកំពង់

សោម ដូចបានបង្ហាញនៅកថាខណ្ឌ ១០(ក)នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ៦១, ៨៦គ និង ៨៦ឃនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៥) បទចោទប្រកាន់ទាំងអស់អំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងកម្មាភិបាលកងពលលេខ ១១៧ និងកម្មាភិបាលតំបន់ ៥០៥ ខេត្តក្រចេះ ដូចបានបង្ហាញនៅកថាខណ្ឌ ១០(ខ)នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ១២ ដល់ ១៤ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

៦) បទចោទប្រកាន់ទាំងអស់អំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងជនបរទេស ក្រៅពីជនជាតិវៀតណាម និងថៃ ដូចបានបង្ហាញនៅកថាខណ្ឌ ១០(គ)នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ៦១ និង ៩៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៧) បទចោទប្រកាន់ទាំងអស់អំពីការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ“ជាតិពន្ធុ” ដូចបានបង្ហាញនៅកថាខណ្ឌ ៧ នៃដីកាសម្រេចថ្ងៃទី ៣ ខែ មីនា។ ចំណុចនេះទាក់ទងនឹងកថាខណ្ឌ ៥៩ ដល់ ៦១ និង ៩៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ស.ច.ស.អ បានប្រកាសថែមទៀតថា ទម្រង់នៃការទទួលខុសត្រូវតាមរយៈការញុះញង់ ឬការជួយ និងជំរុញឱ្យមានឧក្រិដ្ឋកម្ម ត្រូវបានលុបចោលចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិទាំងអស់ ដែលជាបទចោទប្រកាន់នៅក្នុងដីកាសម្រេចថ្ងៃទី៣ ខែ មីនា។

ស.ច.ស.អ បានប្រកាសថា ឥឡូវនេះ ដីកាបង្គាប់ឱ្យនាំខ្លួនចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ លែងមានសុពលភាព ហើយដីកាបង្គាប់ឱ្យនាំខ្លួនចុះថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ត្រូវបានលុបចោល។

មាស មុត ត្រូវបានជូនដំណឹងថា បទចោទប្រកាន់ដែលបានធ្វើឡើងនៅក្នុងការបង្ហាញខ្លួនលើកដំបូងនេះ គឺជាបទចោទប្រកាន់ស្ថាពរប្រឆាំងគាត់នៅពេលនេះ។ ហេតុដូច្នេះ បទចោទប្រកាន់នានានៅក្នុងដីកាសម្រេចថ្ងៃទី៣ ខែ មីនា ដែលបានដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* លែងមានសុពលភាព។

ស.ច.ស.អ បានជូនដំណឹង មាស មុត ទៀតថា មុនពេលបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស.អ អាចសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀត ដោយផ្អែកតាមការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬ

ដីកាសន្និដ្ឋានណាមួយនាពេលអនាគតមកពី ក.ស.ព ប្រសិនបើ ស.ច.ស.អ ជឿជាក់ថា មានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថា មាស មុត អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋបែបនោះ។ ពេលនោះ គាត់នឹងត្រូវបានកោះហៅឱ្យមកបង្ហាញខ្លួនម្តងទៀត និងទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា នៅគ្រប់ពេលទាំងអស់នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់តុលាការ គាត់មានសិទ្ធិស្នើឱ្យ ស.ច.ស.អ ចេញដីកា ឬចាត់វិធានការស៊ើបអង្កេតដែលគាត់យល់ថា មានប្រយោជន៍សម្រាប់ការស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥ (១០) និង ៥៨(៦)។ គាត់ក៏ត្រូវបានជូនដំណឹងទៀតថា គាត់នឹងទទួលបានពេលវេលាសមហេតុផលដើម្បីពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ។ មេធាវីរបស់គាត់ មានសិទ្ធិពិគ្រោះជាមួយនឹងសំណុំរឿងដើម អាស្រ័យតាមដែនកំណត់សមហេតុផល ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីបន្តដំណើរការទៅមុខ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៥៥(១១)។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា នៅពេលនេះ គាត់នឹងមិនជាប់ឃុំខ្លួនបណ្តោះអាសន្នទេ ប៉ុន្តែ គាត់ត្រូវតែបង្ហាញខ្លួនតាមតម្រូវការរបស់ អ.វ.ត.ក។

លោក មាស មុត បានប្រកាសថា គាត់ស្ម័គ្រចិត្តទទួលការចុះត្រួតពិនិត្យប្រចាំសប្តាហ៍ពីនគរបាលនៅគេហដ្ឋានរបស់គាត់។ គាត់បានប្រកាសទៀតថាគាត់មានតែលិខិតឆ្លងដែនដែលផុតសុពលភាព ៥ឆ្នាំ ទៅហើយ។ មាស មុត យល់ព្រមថា គាត់នឹងជូនដំណឹង ស.ច.ស.អ នៅពេលដែលគាត់មានបំណងចាកចេញទៅក្រៅប្រទេសដើម្បីព្យាបាលសុខភាព និង ពេលត្រឡប់មកដល់វិញ។

មាស មុត ថ្លែងថា ប្រសិនបើមានករណីសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ គាត់អាចចេញទៅប្រទេសថៃភ្លាមៗ ហើយ ក្នុងករណីនេះ សហមេធាវីរបស់គាត់នឹងជូនដំណឹងអអើ សចៅក្រមស៊ើបអង្កេតភ្លាមៗ ក្រោយពីទទួលបានដំណឹងពីគាត់។

ស.ច.ស.អ បានប្រកាសថា ចំពោះបញ្ហានេះ គាត់នឹងចេញដីកាបង្គាប់ទៅនគរបាលយុត្តិធម៌របស់ អ.វ.ត.ក ក្នុងថិរវេលាសមស្រប។

មាស មុត បានប្រកាសថា បច្ចុប្បន្ននេះ គាត់ស្នាក់នៅ៖ [redacted]។

ស.ច.ស.អ បានជូនដំណឹង មាស មុត ថា គាត់ត្រូវតែជូនដំណឹង ស.ច.ស.អ ប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋាន។ ស.ច.ស.អ បានជូនដំណឹង មាស មុត ថា តាមវិធាន ៥៧(៣)(ខ)នៃវិធានផ្ទៃក្នុង រាល់ការប្រគល់ឯកសារនានា ឬការជូនដំណឹងទាំងអស់ទៅតាមអាសយដ្ឋានចុងក្រោយនេះនឹងត្រូវចាត់ទុកថាមានសុពលភាព។

មាស មុត បានយល់ព្រមឱ្យប្រគល់ឯកសារនានាទៅគាត់តាមរយៈអ៊ីមែលផ្ញើទៅសហមេធាវីណាម្នាក់ ឬច្រើននាក់ក្នុងចំណោមសហមេធាវីរបស់គាត់។

សំណៅដើមនៃខ្សែអាត់ជាសំឡេង/រូបភាពនៃការបង្ហាញខ្លួនលើកដំបូងនេះ ត្រូវបានប្រថាប់ត្រានៅចំពោះមុខ មាស មុត និងសហមេធាវីរបស់គាត់។ បន្ទាប់ពីសវនាការបង្ហាញខ្លួនលើកដំបូងនេះ ខ្សែអាត់ជាសំឡេង/រូបភាពនេះនឹងត្រូវបើកនៅភ្នំពេញ នៅចំពោះមុខសហមេធាវីរបស់ មាស មុត ឬតំណាងដែលសហមេធាវីបានជ្រើសរើស ហើយសំណៅថតចម្លងមួយច្បាប់នៃខ្សែអាត់ជាសំឡេង/រូបភាពនេះនឹងត្រូវធ្វើឡើង ប្រថាប់ត្រា ហើយប្រគល់ជូនទៅសហមេធាវី ឬតំណាងរបស់សហមេធាវី។

មាស មុត បានលះបង់សិទ្ធិដោយមិនឱ្យអានកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះ ជាភាសាខ្មែរទេ។

មាស មុត មិនមានការជំទាស់ ហើយបានយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុនេះ។

សំណៅមួយច្បាប់នៃកំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងនេះបានប្រគល់ជូន មាស មុត ជាភាសាខ្មែរ។

ការបង្ហាញខ្លួនលើកដំបូងនេះបានបញ្ចប់នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ១០:៤២ នាទី។

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

*ហត្ថលេខា*

**មាស មុត**
**ជនត្រូវចោទ**

*ហត្ថលេខា/ស្នាមមេដៃ*

**Michael Karnavas**
**សហមេធាវីអន្តរជាតិរបស់**
**មាស មុត**

*ហត្ថលេខា*

**អាង ឧត្តម**
**សហមេធាវីជាតិរបស់ មាស មុត**

*ហត្ថលេខា*

**សួរ សុខាល័យ**
**អ្នកបកប្រែភាសា**

*ហត្ថលេខា*

**ឆាយ ចំន្ទលីដា**
**ក្រឡាបញ្ជី**

*ហត្ថលេខា*